# ការបង្កើនសមត្ថភាពរបស់គណៈកម្មការទ្រទ្រង់សាលារៀន នាំឱ្យអត្រាពិតនៃការសិក្សាកើនឡើងកាន់តែខ្ពស់

ដោយសារឥឡូវនេះសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនបានដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ដូច្នេះពួកគេកំពុងតែខិតខំប្រឹងប្រែងដើម្បីប្រមូលកុមារចូលរៀននៅទូទាំងខេត្តមណ្ឌលគិរី។

អំ សល់ ដែលជាកសិករ និងជាចាស់ទុំនៅក្នុងភូមិបានចាំថាពីមុននៅក្នុងភូមិពូហ្យាមនេះ "មិនមានអ្វីនោះទេ"។

ស្ត្រីជនជាតិភាគតិចព្នងវ័យ៥៥ឆ្នាំរូបនេះរំលឹកថា ៖ "មុំនេះគ្មានផ្លូវ និងសាលារៀនទេ"។ គាត់សង្កេតថា ៖ "ឥឡូវនេះមានសាលារៀននៅជិតផ្ទះរបស់យើង"។

[គាត់និយាយថា] ៖ "ខ្ញុំចង់ឱ្យចៅៗរបស់ខ្ញុំទទួលបានការអប់រំ។ បើមានការអប់រំ នោះពួកគេអាចមានការងារល្អធ្វើប្រហែលអាចក្លាយជាគ្រូបង្រៀន"។

គាត់បានសម្រេចចិត្តបញ្ជូនចៅប្រុសដែលមានអាយុ ៤ឆ្នាំរបស់គាត់ឈ្មោះ ប៉ាង សម្បត្តិ ទៅរៀននៅសាលាបឋមសិក្សាក្នុងភូមិក្រោយយុទ្ធនាការប្រមូលកុមារចូលរៀន ដែលរៀបចំឡើងដោយគណៈកម្មការទ្រទ្រង់សាលារៀន។

គាត់ពន្យល់ច្បាស់ៗថា ៖ "គណៈកម្មការទ្រទ្រង់សាលារៀនបាន និងកំពុងប្រមូលកុមារចូលរៀនតាមរយៈយុទ្ធនាការប្រមូលកុមារចូលរៀន។ សមាជិកគណៈកម្មការបានចុះតាមផ្ទះមួយទៅផ្ទះមួយដើម្បីប្រាប់ឪពុកម្តាយអំពីសារៈសំខាន់នៃការរៀនសូត្រ និងការចុះឈ្មោះកូនចូលរៀន"។

គាត់និយាយថា ៖"ដូច្នេះហើយទើបយើងបានសម្រេចចិត្តចុះឈ្មោះចៅយើងចូលរៀន"។ គាត់បានបន្ថែមថា ៖ "មានក្មេងៗ ៤នាក់នៅក្នុងផ្ទះ ហើយយើងនឹងបញ្ជូនពួកគេទៅរៀនទាំងអស់គ្នា"។

អង្គការឃែរកម្ពុជាបាន និងកំពុងជួយគាំទ្រសាលាបឋមសិក្សាពូហ្យាមជិត២ឆ្នាំហើយមកទល់ឥឡូវនេះ។ តាមរយៈគ្រូបង្គោលនៃការិយាល័យអប់រំស្រុក អង្គការឃែរកម្ពុជាបានបង្រៀនសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ដូចជាការប្រមូលកុមារចូលរៀននៅសាលាបឋមសិក្សាជាដើម។

ចែម សុភ័ក្រ្ត នាយិកាសាលាបឋមសិក្សាពូហ្យាម ដឹងច្បាស់អំពីសកម្មភាពនៃគណៈកម្មការទ្រទ្រង់សាលារៀនរបស់គាត់។ ស្ត្រីមានកូនពីរនាក់រូបនេះនិយាយថា ៖ "សមាជិកគណៈកម្មការទ្រទ្រង់សាលារៀនបានដឹងរួចហើយអំពីតួនាទីរបស់ពួកគេកាលពីវគ្គសិក្ខាសិលាដំបូង។ ឥឡូវពួកគេមានតំបន់គោលដៅរបស់ខ្លួន ហើយពួកគេព្យាយាមចុះតាមផ្ទះទាំងអស់"។


© Nicolas Axelrod / Ruom / CARE

*"ខ្ញុំចង់ឱ្យចៅៗរបស់ខ្ញុំទទួលបានការអប់រំ។ បើមានការអប់រំនោះ ពួកគេអាចមានការងារល្អធ្វើប្រហែលអាចក្លាយជាគ្រូបង្រៀន"។*

គាត់និយាយថា ដោយសារតែចំណេះដឹង និងសកម្មភាពបន្តបន្ទាប់របស់គណៈកម្មការដែលមានការប្តេជ្ញាចិត្ត ទើបនាំឱ្យអត្រាពិតនៃការសិក្សាក្នុងឆ្នាំសិក្សានេះកើនឡើងក្នុងចំនួនច្រើន គឺថាអត្រាពិតនៃការសិក្សាក្នុងឆ្នាំសិក្សានេះមានចំនួនទ្វេដងនៃឆ្នាំសិក្សាមុន។

[គាត់បញ្ជាក់ថា] ៖ "ឆ្នាំនេះមានកុមារ ៤២នាក់ចូលរៀនថ្នាក់ទី១ ឯឆ្នាំមុនមានកុមារចុះឈ្មោះចូលរៀនតែ ២១នាក់ប៉ុណ្ណោះ។ ខ្ញុំគិតថាការកើនឡើងនេះគឺដោយសារតែគណៈកម្មការទ្រទ្រង់សាលារៀនដឹងអំពីតួនាទីរបស់ពួកគេ។ ដោយសារឥឡូវនេះពួកគេបានដឹងអំពីតួនាទី និងដឹងថាពួកគេត្រូវប្រមូលសិស្សចូលរៀន ទើបអត្រាពិតនៃការសិក្សាមានកម្រិតកាន់តែខ្ពស់"។

ការយល់ឃើញរបស់គាត់ត្រូវបាននិយាយបន្ទរដោយ លោក ទឹម សង្វាត ប្រធានមន្ទីរអប់រំខេត្តមណ្ឌលគិរី។

លោក សង្វាត ដែលបានកាន់មុខតំណែងជាប្រធានមន្ទីរតាំងពីឆ្នាំ២០០៣ មានប្រសាសន៍ថា ៖ "យុទ្ធនាការប្រមូលកុមារចូលរៀនជាសកម្មភាព ដែលសំខាន់បំផុតមួយរបស់គណៈកម្មការទ្រទ្រង់សាលារៀន"។

[គាត់បន្ថែមថា] ៖ "យើងមានការកើនឡើងនូវអត្រាពិតនៃការសិក្សាក្នុងឆ្នាំនេះ។ យើងមានការកើនឡើងរាល់ឆ្នាំ"។

**These activities are part of the *School Governance* project, which is supported by the Capacity Development Partnership Fund.**

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF)

*© CARE Cambodia, September 2016*